**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ : ២១៦០ សរ.សណ

ថ្ងៃ ពុធ ១៣ រោច ខែ ស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០១៩

## ជម្រាបមក

## ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ** : ស្តីពីការជំរុញការអនុវត្តសកម្មភាព ឬគម្រោងសេវាសង្គមប្រចាំឆ្នាំ របស់រដ្ឋបាលរាជធានី ខេត្ត។

**យោង** : -ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-លិខិតលេខ៥៩៦៣សហវ.អរតន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់ចំណាយលើការអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គមសម្រាប់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

-ផែនការសកម្មភាពឆ្នាំ២០១៩-២០២០ របស់ក្រសួងមហាផ្ទៃ និងអង្គការយូនីសេហ្វ(UNICEF)

-របាយការណ៍លទ្ធផលសិក្ខាសាលា ស្តីពីការរៀបចំបញ្ចូលគម្រោងសេវាសង្គមទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩នៅខេត្តកំពង់ចាម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត** ជ្រាបថា ក្រសួងមហាផ្ទៃ សូមកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលរាជធានី ខេត្ត ដែលបានយកចិត្តទុកដាក់វិភាជន៍ថវិកា យ៉ាងតិច៥% នៃថវិកាគុណប្រយោជន៍ ឬថវិកាអភិវឌ្ឍប្រចាំឆ្នាំខ្លួន ក្នុងការគាំទ្រ និងអនុវត្តគម្រោងសេវាសង្គមស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ។ ការចូលរួមអនុវត្តគម្រោងសេវាសង្គម គឺមានសារៈសំខាន់ និងបានផ្តល់អត្ថប្រយោជន៍ជួយសម្រាលនូវទុក្ខលំបាករបស់ប្រជាពលរដ្ឋក្រីក្រ និងងាយរងគ្រោះ ដែលសកម្មភាពមួយចំនួន គឺជាមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវពិចារណា ឆ្លើយតបឱ្យបានសមស្របទៅតាមលទ្ធភាព និងតាមតម្រូវការចាំបាច់ជាក់ស្តែងនៅតាមមូលដ្ឋាន។

ផ្អែកតាមលទ្ធផល នៃអង្គសិក្ខាសាលា ស្តីពីការរៀបចំបញ្ចូលគម្រោងសេវាសង្គមទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ ជាពិសេស ដើម្បីឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង នៃការអនុវត្តគម្រោងសេវាសង្គម នៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

១-រដ្ឋបាលរាជធានី ខេត្ត ត្រូវលើកគម្រោង និងត្រូវវិភាជន៍ថវិកា ដើម្បីអនុវត្តសកម្មភាព ឬគម្រោងសេវាសង្គម យ៉ាងតិច ៥% (ប្រាំភាគរយ) នៃថវិកាគុណប្រយោជន៍ (ថវិកាអភិវឌ្ឍ) ប្រចាំឆ្នាំនីមួយៗ (ដូចមានតារាងគំរូជូនភ្ជាប់) ដើម្បីជួយដល់ជនក្រីក្រ និងក្រុមជនងាយរងគ្រោះ ជាពិសេសស្ត្រី កុមារ ជនមានពិការភាព និងចាស់ជរាគ្មានទីពឹង។ ទន្ទឹមនេះ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវស្វែងយល់អំពីតម្រូវការ នៃសេវាសង្គមចាំបាច់ជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន ដោយពិភាក្សាជាមួយមន្ទីរ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ដើម្បីរៀបចំផែនការឆ្លើយតប និងដាក់ថវិកាសម្រាប់អនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម ដែលភាគច្រើនគម្រោង ឬសកម្មភាពសេវាសង្គមទាំងនេះ គឺជាមុខងារជាជម្រើស ឬមុខងារជាអាណត្តិទូទៅ ឬអាចពិនិត្យលទ្ធភាពជ្រើសរើសគម្រោងសេវាសង្គមដូចមានចែងក្នុងឯកសារតម្រង់ទិស៖ បញ្ជី (ជម្រើស) មុខសញ្ញាចំណាយគម្រោងសេវាសង្គម។

20190805 WS Report on Social Service Budget final DDC

២-រដ្ឋបាលរាជធានី ខេត្ត ត្រូវអនុវត្តតាមខ្លឹមសារលិខិតលេខ៥៩៦៣ សហវ.អរតន ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់ការចំណាយលើការអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម សម្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង តារាងជំនួយស្មារតីស្តីពីបញ្ជី (ជម្រើស) មុខសញ្ញាចំណាយ និងមាតិកាថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច សម្រាប់ចំណាយសេវាសង្គម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ដូចមានក្នុងឯកសារជូនភ្ជាប់)។

៣-រដ្ឋបាលរាជធានី ខេត្ត ត្រូវណែនាំ និងជំរុញ គាំទ្រដល់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការសិក្សាស្វែងយល់អំពីតម្រូវការនៃសេវាសង្គមនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការដាក់បញ្ចូលនូវគម្រោងសេវាសង្គមចាំបាច់ និងជាអាទិភាពឱ្យបានជាអតិបរមា ស្របតាមតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួន ក៏ដូចក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិល។

៤-ចំពោះរដ្ឋបាលរាជធានី ខេត្ត គោលដៅទាំងប្រាំពីរ ដែលបានរៀបចំគម្រោងថវិកាសម្រាប់អនុវត្តសកម្មភាព ឬគម្រោងសេវាសង្គមឆ្នាំ២០១៩ និងឆ្នាំ២០២០ នៅក្នុងសិក្ខាសាលា ស្តីពីការរៀបចំបញ្ចូលគម្រោងសេវាសង្គមទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំ (ដូចមានក្នុងឯកសារជូនភ្ជាប់) ត្រូវបន្តជំរុញ និងគាំទ្រការអនុវត្តគម្រោងសេវាសង្គម ទាំងនោះឱ្យសម្រេចបានជោគជ័យតាមការគ្រោងទុក។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវអភិបាល** នៃគណៈអភិបាលរាជធានី ខេត្ត ជ្រាប និងចាត់ចែងឲ្យមានប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវអភិបាល** ទទួលនូវការរាប់អាន ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>ចម្លងជូន:</u>

*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-ក្រសួងផែនការ*
*-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*
*-អង្គការ Unicef ប្រចាំនៅកម្ពុជា*
*(ដើម្បីជូនជ្រាប)*
*-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលរាជធានី/ខេត្ត .......................

## គម្រោង សកម្មភាពវិនិយោគប្រចាំ ដែលមានថវិកា គាំទ្រដោយរដ្ឋបាលរាជធានី/ខេត្ត
## ប្រចាំឆ្នាំ២០២...

| ល.រ | ឈ្មោះគម្រោង សកម្មភាព | ទីតាំង | លទ្ធផលគម្រោង | | រយៈពេលអនុវត្ត | តម្លៃ | ប្រភពមូលនិធិ (ប្រចាំឆ្នាំ/ថវិកាបន្ថែម) | កម្រិតទុនវិនិយោគ ប្រចាំឆ្នាំ (លានរៀល) | អង្គភាពអនុវត្ត | និដៅគម្រោង (សេវាសង្គម) |
|---|---|---|---|---|---|---|---|---|---|---|
| | | | បរិមាណ | ឯកតា | | | | | | |
| ១.ផ្នែកសេដ្ឋកិច្ច | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ២.ផ្នែកសង្គមកិច្ច | | | | | | | | | | |
| | | | | | | | | | | ✓ |
| | | | | | | | | | | ✓ |
| | | | | | | | | | | |
| ៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |
| ៤.ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

## គម្រោងត្រៀមសម្រាប់អនុវត្ត នៅពេលដែលរាជធានី ខេត្ត ទទួលបានថវិកាបន្ថែម *

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | |
| | | | | | | | | | | |
| | | | | | | | | | | |

## ថវិកា គម្រោង/សកម្មភាព និងសមមាត្រ នៃទំហំថវិកា

| ល.រ | បរិយាយ | ថវិកា (លានរៀល) | សមមាត្រ នៃទំហំ ថវិកា (%) | ចំនួនគម្រោង/ សកម្មភាព |
|---|---|---|---|---|
| ១ | ថវិការបស់រដ្ឋបាលរាជធានី ខេត្ត សរុប (លានរៀល) | ១០០០ | | |
| ២ | ចំនួនគម្រោង និងថវិកាអភិវឌ្ឍ ឬថវិកាគុណប្រយោជន៍សរុប (លានរៀល) | ៥០០ | | ១០ |
| ៣ | ចំនួនគម្រោង និងថវិកាអនុវត្តគម្រោង ឬសកម្មភាពសេវាសង្គម សរុប (លានរៀល) | ៥០ | | ២ |
| ៤ | សមមាត្រ នៃទំហំថវិកាធៀបនិងថវិកាអភិវឌ្ឍ ឬថវិកាគុណប្រយោជន៍សរុប (%) | | ១០% | |
| ៥ | សមមាត្រ នៃទំហំថវិកាធៀបនិងថវិការបស់រដ្ឋបាលរាជធានី ខេត្ត សរុប (%) | | ៥% | |

សំគាល់៖ -តារាងនេះត្រូវរៀបចំដោយដកស្រង់គម្រោងចេញពីកម្មវិធីវិនិយោគបីឆ្នាំរំកិលដែលនៅជាធរមាន និងគម្រោងអាទិភាពដែលឆ្លើយបតនឹងតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

-តារាងនេះត្រូវផ្ញើមកអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ យ៉ាងយូរត្រឹមថ្ងៃទី ថ្ងៃទី០១ ខែតុលា មុនឆ្នាំអនុវត្តថវិកា

*គម្រោងនេះ គឺជាគម្រោងដែលមិនទាន់មានថវិកាគាំទ្រ ប៉ុន្តែដើម្បីត្រៀមសម្រាប់អនុវត្ត នៅពេលដែលរាជធានី ខេត្ត ទទួលបានថវិកាបន្ថែម។

លេខ:............................................

......................ថ្ងៃទី.................ខែ..........ឆ្នាំ២០១៩ ................. ថ្ងៃទី..........ខែ.................ឆ្នាំ២០១៩

**អភិបាល** **នាយករដ្ឋបាល** **អ្នកធ្វើតារាង**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ. [illegible]

**សូមគោរពជូន**
**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ៖** ករណីសំណើសុំកំណត់មាតិកាថវិកា និងលិខិតយុត្តិការចំណាយសម្រាប់ទូទាត់ការចំណាយលើការអនុវត្តគម្រោង ឬ សកម្មភាពសេវាសង្គបសប្រាប់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**យោង៖** - លិខិតលេខ២០៥២ ល.ស ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ
- ប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនីនិងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន សម្តេចក្រឡាហោម **ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ ដើម្បីបង្កើនការចូលរួមគាំទ្រ និងជំរុញសកម្មភាពសេវាសង្គមរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនភ្ជាប់នូវតារាងបញ្ជី (ជម្រើស) មុខសញ្ញាចំណាយនិងមាតិកាចំណាយតាមចំណាត់ថ្នាក់សេដ្ឋកិច្ច លើការងារអនុវត្តគម្រោងសេវាសង្គម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សម្រាប់ជាឯកសារជំនួយស្មារតីដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការគ្រោងថវិកានិងអនុវត្តចំណាយលើការអនុវត្តគម្រោង ឬ សកម្មភាពសេវាសង្គម ឱ្យបានត្រឹមត្រូវស្របតាមប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសលេខ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួល និងការបង្កើតបន្ថែមគណនីនិងអនុគណនីនៃចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានៃប្រកាសលេខ៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ទន្ទឹមនេះ ដើម្បីសម្រួលដល់ការអនុវត្តចំណាយលើការអនុវត្តគម្រោង ឬ សកម្មភាពសេវាសង្គមរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានត្រឹមត្រូវស្របតាមនីតិវិធីហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំបន្ថែម ដូចខាងក្រោម៖

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

១-ចំពោះចំណាត់ថ្នាក់កម្មវិធី÷ រដ្ឋបាលរាជធានី ខេត្ត ដែលអនុវត្តថវិកាម្មវិធី ត្រូវគ្រោងចំណាយសកម្មភាព សេវាសង្គមរួមទាំងសកម្មភាពជួសជុល និងសាងសង់ នៅក្នុងចង្កោមសកម្មភាពទី១ នៃអនុកម្មវិធីទី១ ក្នុងកម្មវិធីទី២ សម្រាប់មាតិកាថវិកាកម្មវិធី។ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

២-ចំពោះចំណាត់ថ្នាក់សេដ្ឋកិច្ច÷ សូមមើលការកំណត់លម្អិតនៅក្នុងតារាងជំនួយស្មារតីភ្ជាប់ជាមួយនេះ។

៣-ចំពោះសកម្មភាព ឬ មុខសញ្ញាចំណាយដែលត្រូវអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាម÷

- ប្រកាសលេខ២៧៥ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ១៦៧ សហវ.ប្រក ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រកាសលេខ១៥៨៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ១៣ នៃប្រកាស២៧៥ សហវ.ប្រក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទាន សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

៤-ចំពោះចំណាយថវិកាដែលត្រូវអនុវត្តតាមនីតិវិធីធម្មតា (ក្រៅពីរជ្ជទេយ្យបុរេប្រទាន) គឺត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាប និងចាត់ចែង តាមការគួរ។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ពីខ្ញុំ។

ថ្ងៃ ច័ន្ទ ១៤រោច ខែ ជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**តារាងជំនួយស្មារតីស្តីពីបញ្ជី (ជម្រើស) មុខសញ្ញាចំណាយនិងមាតិកាថវិកាតាមចំណាត់ថ្នាក់សេដ្ឋកិច្ច**

**សម្រាប់ចំណាយសេវាសង្គម របស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| ១- សុខភាពមាតា និងកុមារ និង អាហារូបត្ថម្ភ | ការផ្តល់សេវាសុខភាព និង អាហារូបត្ថម្ភ ដល់មាតា និងកុមារ | - ចំណាយសម្រាប់ការធ្វើដំណើររបស់បុគ្គលិកមណ្ឌលសុខភាព/បុគ្គលិកមន្ទីរសុខាភិបាល ក្នុងការចុះពិនិត្យស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ៥ឆ្នាំ ដើម្បីកំណត់រកអ្នកមានបញ្ហាអាហារូបត្ថម្ភ<br>- ចំណាយសម្រាប់ការធ្វើដំណើររបស់បុគ្គលិកមណ្ឌល សុខភាព/បុគ្គលិកមន្ទីរសុខាភិបាល ដើម្បីផ្សព្វផ្សាយបង្កើនការយល់ដឹង និងផ្តល់ការព្យាបាលដល់ម្តាយ និងកុមារដែលមានបញ្ហាអាហារូបត្ថម្ភនៅតាមសហគមន៍ | 60015 "ប្រេងឥន្ធនៈនិងប្រេងរំអិល" | ទិញប្រេងឥន្ធនៈសម្រាប់យាន្តជំនិះរបស់អង្គភាព ឬរបស់បុគ្គលិកមណ្ឌលសុខភាព/បុគ្គលិកមន្ទីរសុខាភិបាល ដើម្បីចុះបំពេញការងារ |
| | | | 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" | ជួលមធ្យោបាយដឹកជញ្ជូន ដើម្បីចុះបំពេញការងារដូចជា÷ កង់ ម៉ូតូ រថយន្ត ជាដើម |
| | | | 61121 "សោហ៊ុយដឹកជញ្ជូន"<br>61122 "សោហ៊ុយបេសកកម្ម"<br>61123 "សោហ៊ុយស្នាក់នៅ" | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា ដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្ម ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពី រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | -ចំណាយសម្រាប់រៀបចំបណ្តុះបណ្តាល/កិច្ចប្រជុំបង្កើនការយល់ដឹងតាមសហគមន៍ (តាមភូមិ ឬមណ្ឌលសុខភាព ឬនៅសាលាឃុំ សង្កាត់ ឬនៅតាមសាលារៀន) អំពីបញ្ហាសុខភាព និងអាហារូបត្ថម្ភរបស់មាតា និងកុមារ | 61041"សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស" | សកម្មភាពនៃការផ្តល់ចំណេះដឹង ឬ ជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ |
| | | | 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | សកម្មភាពនៃការផ្សព្វផ្សាយការពិគ្រោះយោបល់ ការណែនាំ ឬ ការផ្លាស់ប្តូរបទពិសោធន៍ដល់អ្នកចូលរួមពាក់ព័ន្ធ |
| | ការគាំទ្រឱ្យមាតា និងកុមារទទួលបានសេវាសុខភាព និងអាហារូបត្ថម្ភ | -ចំណាយសម្រាប់ដឹកជញ្ជូនអ្នកជំងឺ (ស្ត្រីមានផ្ទៃពោះ និងកុមារដែលមានបញ្ហាអាហារូបត្ថម្ភ និងកុមារពិការ) មកពីគ្រួសារក្រីក្រ ដើម្បីរកទទួលបានការព្យាបាលនៅមណ្ឌលសុខភាព និង/ឬមន្ទីរពេទ្យ<br>-ចំណាយសម្រាប់ដឹកជញ្ជូនស្ត្រីមានផ្ទៃពោះ និងទារកទើបនឹងកើត(មកពីគ្រួសារក្រីក្រ) ទៅមណ្ឌលសុខភាព និង/ឬមន្ទីរពេទ្យ ដើម្បីពិនិត្យផ្ទៃពោះ និងទទួលបានការថែទាំក្រោយសម្រាល | 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" | ជួលមធ្យោបាយដឹកជញ្ជូនដើម្បីដឹកជញ្ជូនអ្នកជំងឺ និងស្ត្រីមានផ្ទៃពោះ ទៅមណ្ឌលសុខភាព និង/ឬមន្ទីរពេទ្យ ដូចជា÷ កង់ ម៉ូតូរ៉ឺម៉ក ត្រីចក្រយានយន្ត រថយន្ត ជាដើម |
| | | -ផ្តល់ (ប្រាក់ឧបត្ថម្ភ)ជំនួយសង្គមសម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារមកពីគ្រួសារក្រីក្រ ក្នុងកំឡុងពេលដែលពួកគេទទួលបានការព្យាបាលបញ្ហាអាហារូបត្ថម្ភ | 62028 "ជំនួយសង្គមផ្សេងៗទៀត" | |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | ការសាងសង់/ការជួសជុលមូលដ្ឋានសុខាភិបាល | -ការចំណាយសម្រាប់សាងសង់មណ្ឌលសុខភាពថ្មី/ជួសជុលមណ្ឌលសុខភាពមានស្រាប់ | 21031 “សំណង់អគារ” | សម្រាប់ការសាងសង់អគារថ្មី (ស្ថិតក្នុងចំណាយមូលធន) |
| | | | 21032 “កែលំអអគារ” | សម្រាប់ការជួសជុល/កែលម្អអគារ (ស្ថិតក្នុងចំណាយមូលធន) |
| | | | 61052 “ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ” | ចំណាយលើការថែទាំ ជួសជុលអគារ ដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ |
| | | | 60012 “សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ” | ចំណាយលើការទិញសម្ភារៈសម្រាប់ការងារថែទាំ និងជួសជុលអគារ ដែលធ្វើដោយមន្ត្រីរបស់អង្គភាព |
| ២- ទឹកស្អាត និងអនាម័យ | ការផ្គត់ផ្គង់ទឹកស្អាតនិងការផ្តល់សេវាអនាម័យនៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | -ចំណាយសម្រាប់ការជួសជុល/សាងសង់កន្លែងលាងដៃ បង្គន់ នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 61052 “ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ” | ចំណាយលើការជួសជុល/សាងសង់កន្លែងលាងដៃ បង្គន់ ដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ |
| | | | 60012 “សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ” | ចំណាយលើការទិញសម្ភារៈសម្រាប់ការជួសជុល/សាងសង់កន្លែងលាងដៃ បង្គន់ ដែលធ្វើដោយមន្ត្រីរបស់អង្គភាព |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ចំណាយសាងសង់និងជួសជុលអណ្តូងទឹកនិងការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 61054 "ការថែទាំបណ្តាញផ្សេងៗ" | ចំណាយលើការសាងសង់និងជួសជុលអណ្តូងទឹក និងការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹកដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ |
| | | | 60012 "សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ" | ចំណាយលើការទិញសម្ភារៈសម្រាប់សាងសង់និងជួសជុលអណ្តូងទឹក និងការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹកដែលធ្វើដោយមន្ត្រីរបស់អង្គភាព |
| | | បំពាក់ម៉ាស៊ីនឬប្រព័ន្ធចម្រោះទឹកស្អាតនៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 60051 "សម្ភារៈនិងបរិក្ខារបច្ចេកទេសមិនមែនព័ត៌មានវិទ្យា" | |
| | | ការផ្តល់សាប៊ូ និងសម្ភារៈសម្អាតអនាម័យ នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 60011 "សម្ភារផ្គត់ផ្គង់សម្អាត និងអនាម័យ" | |
| | | ការផ្តល់ធុងទឹក នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 60053 "សម្ភារៈប្រើប្រាស់" | |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ទិញបង្គន់ចល័តសម្រាប់ប្រើប្រាស់នៅតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) នៅតាមមូលដ្ឋានសុខាភិបាល និងតាមទីសាធារណៈ | 60058 "ការទិញសម្ភារៈតូចតាច សង្ហារឹម និងសម្ភារៈបរិក្ខារផ្សេងៗ" | |
| | | -ចំណាយសម្រាប់ការធ្វើដំណើររបស់បុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីរៀបចំកិច្ចប្រជុំបង្កើនការយល់ដឹង រៀបចំនិងអនុវត្តផែនការលើកកម្ពស់ទឹកស្អាត និងអនាម័យតាមសាលារៀន(រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល<br>-ចំណាយធ្វើដំណើរសម្រាប់ឱ្យបុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ទីរអប់រំ យុវជន និងកីឡា ចុះពិនិត្យតាមដាន<br>- ចំណាយសម្រាប់ការធ្វើដំណើររៀបចំកិច្ចប្រជុំបំផុស រៀបចំនិងអនុវត្តផែនការសម្រាប់សហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅតាមសហគមន៍នានា | 60015 "ប្រេងឥន្ធនៈនិងប្រេងរំអិល" | ទិញប្រេងឥន្ធនៈសម្រាប់យានជំនិះរបស់អង្គភាព ឬរបស់បុគ្គលិកមណ្ឌលសុខភាព/បុគ្គលិកមន្ទីរអភិវឌ្ឍជនបទ និងមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីចុះបំពេញការងារ |
| | | | 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" | ជួលមធ្យោបាយដឹកជញ្ជូន ដើម្បីចុះបំពេញការងារដូចជា÷ កង់ ម៉ូតូ រ៉ឺម៉ក ត្រីចក្រយានយន្ត រថយន្ត ជាដើម |
| | | | 61121 "សោហ៊ុយដឹកជញ្ជូន"<br>61122 "សោហ៊ុយបេសកកម្ម"<br>61123 "សោហ៊ុយស្នាក់នៅ" | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យា ដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្មស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពី រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | ការផ្គត់ផ្គង់ទឹកស្អាត និង ការផ្តល់សេវាអនាម័យ នៅ សហគមន៍និងតាមគ្រួសារ | -ចំណាយសម្រាប់រៀបចំវគ្គបំផុសសហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅតាមសហគមន៍<br>-ចំណាយសម្រាប់បុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទរៀបចំកិច្ចប្រជុំអំពីការគ្រោងផែនការនិងអនុវត្តផែនការសម្រាប់សហគមន៍ដឹកនាំអនាម័យទាំងស្រុងនៅតាមសហគមន៍<br>-ចំណាយសម្រាប់បុគ្គលិកមន្ទីរអភិវឌ្ឍន៍ជនបទរៀបចំកិច្ចប្រជុំបង្កើនការយល់ដឹងលើការរៀបចំនិងអនុវត្តផែនការលើកកម្ពស់ទឹកស្អាត និងអនាម័យតាមសាលារៀន (រួមទាំងសាលាមត្តេយ្យ) និងនៅតាមមូលដ្ឋានសុខាភិបាល | 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស" | សកម្មភាពនៃការផ្តល់ចំណេះដឹង ឬ ជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ |
| | | | 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | សកម្មភាពនៃការផ្សព្វផ្សាយការពិគ្រោះយោបល់ ការណែនាំ ឬ ការផ្លាស់ប្តូរបទពិសោធន៍ដល់អ្នកចូលរួមពាក់ព័ន្ធ |
| | | -ចំណាយឧបត្ថម្ភដល់សហគមន៍សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងការផ្តល់សេវាអនាម័យ ដូចជា÷ ការសាងសង់ និងជួសជុលអណ្តូងទឹក/បង្គន់ និងការតភ្ជាប់បណ្តាញផ្គត់ផ្គង់ទឹក, ការទិញបង្គន់ចល័តនៅតាមសហគមន៍ ជាដើម | 62031 "ឧបត្ថម្ភសហគមន៍ និងរក្សាសណ្តាប់ធ្នាប់សន្តិសុខសង្គម" | ចំណាយឧបត្ថម្ភដល់សហគមន៍លើកលែងសហគមន៍កីឡានិងវប្បធម៌ដែលត្រូវប្រើប្រាស់អនុគណនី៦២០៣៥ "ឧបត្ថម្ភសហគមន៍ កីឡា និងវប្បធម៌" |
| ៣-ការអប់រំកុមារតូច | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលាមត្តេយ្យ | ចំណាយសម្រាប់សាងសង់សាលាមត្តេយ្យសហគមន៍ និងសាលាមត្តេយ្យរដ្ឋ | 21031 "សំណង់អគារ" | |
| | | | 60053 "សម្ភារប្រើប្រាស់" | ចំណាយទិញសម្ភារៈកីឡា តង់កៅស៊ូ ជាដើម។ |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ចំណាយលើការរៀបចំ ថែទាំ និងជួសជុលសួនកុមារ នៅតាមសាលាមត្តេយ្យសហគមន៍/ សាលាមត្តេយ្យរដ្ឋ | 60052 “សង្ហារឹម” | ចំណាយទិញតុ កៅអី ជាដើម |
| | | | 60012 “សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារ ប្រាសាទ និងសំណង់ផ្សេងៗ” | ចំណាយលើការទិញសម្ភារៈសម្រាប់ថែទាំ និងជួសជុលសួនកុមារដែលធ្វើដោយមន្ត្រីរបស់អង្គភាព |
| | | | 61052 “ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ” | ចំណាយលើការថែទាំ និងជួសជុលសួនកុមារ ដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ |
| | ដំណើរការសាលាមត្តេយ្យ | ចំណាយ/បៀវត្សរ៍(ប្រាក់ឧបត្ថម្ភ) សម្រាប់គ្រូ ដែលជួលឱ្យបង្រៀននៅតាមសាលាមត្តេយ្យសហគមន៍ | 61093 “បុគ្គលិកសម្ធហភាពសាធារណៈផ្សេងៗ” | យោងប្រកាស១១២៩សហវ.ប្រក ចុះថ្ងៃទី១២ខែតុលាឆ្នាំ២០១៨ |
| | | ចំណាយសំរាប់បំប៉ននិងបណ្តុះបណ្តាល បច្ចេកទេសរៀន និងបង្រៀនគ្រូមត្តេយ្យសហគមន៍មិនជាប់ស្តង់ដាររបស់ក្រសួងអប់រំយុវជននិងកីឡា | 61041 “សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស” | សកម្មភាពនៃការផ្តល់ចំណេះដឹង ឬ ជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ |
| ៤- ការអប់រំបឋមសិក្សា និងមធ្យមសិក្សា | ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាលារៀន | ចំណាយសាងសង់សាលារៀនថ្មីៗនៅតំបន់ដាច់ស្រយាល | 21031 “សំណង់អគារ” | |
| | | ចំណាយលើការរៀបចំ ថែទាំ និងជួសជុលសួនកុមារ និងកន្លែងលេងកីឡា នៅសាលាបឋមសិក្សា និងមធ្យមសិក្សា | 60053 “សម្ភារប្រើប្រាស់” | ចំណាយទិញសម្ភារៈកីឡា តង់កៅស៊ូ ជាដើម។ |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | | 60052 “សង្ហារឹម” | ចំណាយទិញតុ កៅអី ជាដើម |
| | | | 60012 “សម្ភារផ្គត់ផ្គង់សម្រាប់ថែទាំអគារប្រាសាទ និងសំណង់ផ្សេងៗ” | ចំណាយលើការទិញសម្ភារៈសម្រាប់ថែទាំ និងជួសជុលសួនកុមារដែលធ្វើដោយមន្ត្រីរបស់អង្គភាព |
| | | | 61052 “ការថែទាំ ជួសជុលអគារផ្សេងៗ និងប្រាសាទ” | ចំណាយលើការថែទាំ និងជួសជុលសួនកុមារ ដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ ដូចជា÷ របង បន្ទប់ទឹក សួនច្បារ ជាដើម។ |
| | | | 61051 “ការថែទាំដីធ្លី សួនច្បារ ព្រៃឈើ តំបន់ឆ្នេ និងដែននេសាទ” | ចំណាយលើការថែទាំដីធ្លី ដែលជួលសេវាផ្គត់ផ្គង់ពីខាងក្រៅ ដូចជា÷ ការកាប់ឆ្ការព្រៃចាក់ដីបំពេញជាដើម។ |
| | គាំទ្រឱ្យសិស្សមកពីគ្រួសារក្រីក្របន្តរៀនឱ្យចប់ការអប់រំកម្រិតមធ្យមសិក្សា | ចំណាយសម្រាប់ផ្តល់អាហារូបករណ៍ដល់សិស្សមកពីគ្រួសារក្រីក្រ ដើម្បីឱ្យពួកគេបន្តរៀនរហូតដល់បញ្ចប់ថ្នាក់ទី១២ | 62025 “អាហារូបករណ៍សម្រាប់ការសិក្សា-ស្រាវជ្រាវក្នុងប្រទេស” | |
| | | ការផ្តល់អាហារពេលព្រឹកដល់សិស្សមកពីគ្រួសារក្រីក្រតាមសាលារៀន(មត្តេយ្យសហគមន៍ មត្តេយ្យរដ្ឋ និងបឋមសិក្សា) | 62023 “អាហារនិងសម្ភារៈ (ស្បៀង)” | |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | ការកំណត់អត្តសញ្ញាណសិស្សដែលមកពីគ្រួសារក្រីក្រដែលទទួលអាហារូបករណ៍ និងពិនិត្យតាមដាន | -ចំណាយធ្វើដំណើរសម្រាប់មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ចុះកំណត់អត្តសញ្ញាណសិស្សដែលងាយបោះបង់ចោលការសិក្សា<br>-ចំណាយធ្វើដំណើរសម្រាប់មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ ចុះពិនិត្យតាមដាន និង/ឬចុះសួរសុខទុក្ខតាមគ្រួសារ | 60015 “ប្រេងឥន្ធនៈនិងប្រេងរំអិល” | ទិញប្រេងឥន្ធនៈសម្រាប់យានជំនិះរបស់អង្គភាព ឬរបស់មន្ត្រីមន្ទីរអប់រំ យុវជន និងកីឡា ឬការិយាល័យអប់រំ យុវជននិងកីឡាក្រុងស្រុកខណ្ឌ ដើម្បីចុះបំពេញការងារ |
| | | | 61021 “ការជួលមធ្យោបាយដឹកជញ្ជូន” | ជួលមធ្យោបាយដឹកជញ្ជូនដើម្បីចុះបំពេញការងារដូចជា÷ កង់ ម៉ូតូ រ៉ឺម៉ក ត្រីចក្រយានយន្ត រថយន្ត ជាដើម |
| | | | 61121 “សោហ៊ុយដឹកជញ្ជូន”<br>61122 “សោហ៊ុយបេសកកម្ម”<br>61123 “សោហ៊ុយស្នាក់នៅ” | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្មស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |
| ៥- ការការពារស្ត្រី និងកុមារ | | -ចំណាយធ្វើដំណើរសម្រាប់កុមារ ស្ត្រីរងគ្រោះ និងគ្រួសារដើម្បីទៅទទួលសេវា | 60015 “ប្រេងឥន្ធនៈនិងប្រេងរំអិល” | ទិញប្រេងឥន្ធនៈសម្រាប់យានជំនិះ ចុះបំពេញការងារ |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពី រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | -គាំពារជនរងគ្រោះដោយអំពើហិង្សានិងការបំពាននិងគ្រួសារ<br>-គាំទ្រការផ្តល់សេវាគាំពារជនរងគ្រោះដោយអំពើហិង្សានិងការបំពាននិងគ្រួសារ | -ចំណាយធ្វើដំណើរសម្រាប់មន្ត្រីសង្គមកិច្ចនិងមន្ត្រីអនុវត្តច្បាប់ក្នុងពេលអន្តរាគមន៍ជួយកុមារ ស្ត្រីរងគ្រោះនិងគ្រួសារ<br>-ចំណាយធ្វើដំណើរសម្រាប់គ្រូនិងសិក្ខាកាមក្នុងវគ្គបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច (ពាក់កណ្តាលអាជីព)<br>-ចំណាយធ្វើដំណើរសម្រាប់មន្ត្រីសង្គមកិច្ចចុះបើកវគ្គដល់មាតាបិតា និងអ្នកថែទាំកុមារស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន | 61021 “ការជួលមធ្យោបាយដឹកជញ្ជូន” | ជួលមធ្យោបាយដឹកជញ្ជូនដើម្បីចុះបំពេញការងារដូចជា៖ កង់ ម៉ូតូ រថយន្ត ជាដើម |
| | | | 61121 “សោហ៊ុយដឹកជញ្ជូន”<br>61122 “សោហ៊ុយបេសកកម្ម”<br>61123 “សោហ៊ុយស្នាក់នៅ” | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្មស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |
| | -គាំទ្រកម្មវិធីនៅតាមសហគមន៍រួមទាំងគម្រោងលើកកម្ពស់ជីវភាពគ្រួសារងាយរងគ្រោះនិងគ្រួសារក្រីក្រ | -ចំណាយសម្រាប់វគ្គបណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច (ពាក់កណ្តាលអាជីព)<br>-ចំណាយសម្រាប់បើកវគ្គជំនាញវិជ្ជាជីវៈសម្រាប់គ្រួសាររងគ្រោះនិងងាយរងគ្រោះ ព្រមទាំងគ្រួសារក្រីក្រ<br>-ចំណាយសម្រាប់បើកវគ្គដល់មាតាបិតា និងអ្នកថែទាំកុមារ ស្តីពីការចិញ្ចឹមថែទាំកូនតាមបែបវិជ្ជមាន | 61041 “សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស” | សកម្មភាពនៃការផ្តល់ចំណេះដឹង ឬ ជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ |
| | | | 61103 “ប្រជុំ សិក្ខាសាលា និងសន្និសីទ” | សកម្មភាពនៃការផ្សព្វផ្សាយ ការពិគ្រោះយោបល់ ការណែនាំ ឬ ការផ្លាស់ប្តូរបទពិសោធន៍ដល់អ្នកចូលរួមពាក់ព័ន្ធ |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពី រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ចំណាយលើជំនួយសង្គម/ ប្រាក់ឧបត្ថម្ភសម្រាប់កុមារ ស្ត្រីរងគ្រោះ និងគ្រួសារក្នុងអំឡុងពេលទទួលសេវា និងអំឡុងពេលបញ្ជូនត្រឡប់ទៅសហគមន៍ តាមនីតិវិធីប្រព័ន្ធយុត្តិធម៌ | 62028 "ជំនួយសង្គមផ្សេងៗទៀត" | |
| | ការចុះសំបុត្រកំណើត តាមរយៈការដាក់ឱ្យអនុវត្តនូវសៀវភៅកត់ត្រាព័ត៌មានភូមិ | ចំណាយបោះពុម្ពសៀវភៅកត់ត្រាព័ត៌មានភូមិ | 60023 "ការបោះពុម្ព" | |
| | | -ចំណាយសម្រាប់រៀបចំកិច្ចប្រជុំតម្រង់ទិសជាមួយមេភូមិ និងតម្រង់ទិសស្តីពីអត្រានុកូលដ្ឋានគ្រប់ប្រភេទដល់ស្មៀនឃុំ និងជំនួយការឃុំ សង្កាត់<br>-ចំណាយសម្រាប់កិច្ចប្រជុំឆ្លុះបញ្ចាំង | 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | |
| | ពង្រឹងសមត្ថភាពរបស់ស្រុក ក្រុង ដើម្បីចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារដែលដំណើរការដោយអង្គការមិនមែនរដ្ឋាភិបាល និងធ្វើសមាហរណកម្មកុមារចូលទៅក្នុងសហគមន៍ និងគ្រួសាររបស់ពួកគេវិញ | -ចំណាយលើមធ្យោបាយបំពេញការងាររបស់ភ្នាក់ងារសង្គមកិច្ចឃុំ សង្កាត់ និងស្រុក ក្រុង ក្នុងនោះមាន÷ ទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬរ៉ឺម៉ក កុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថតចម្លង និងម៉ាស៊ីនស្កេន ជាដើម។ | 60054 "សម្ភារ និងឧបករណ៍ដឹកជញ្ជូន" | ចំណាយទិញទោចក្រយានយន្ត ត្រីចក្រយានយន្ត ឬរ៉ឺម៉កជាដើម |
| | | | 60055 "សម្ភារនិងបរិក្ខារបច្ចេកទេសព័ត៌មានវិទ្យា" | ចំណាយទិញកុំព្យូទ័រ ព្រីនធ័រ ម៉ាស៊ីនថតចម្លង/ស្កេនជាដើម |
| | | -ចំណាយធ្វើដំណើរសម្រាប់មន្ត្រីស្រុក ក្រុង ក្នុងការចុះធ្វើអធិការកិច្ចមណ្ឌលថែទាំកុមារ<br>-ចំណាយធ្វើដំណើរចុះពិនិត្យតាមដាន/គ្រប់គ្រងករណី | 60015 "ប្រេងឥន្ធនៈនិងប្រេងរំអិល" | ទិញប្រេងឥន្ធនៈសម្រាប់យានជំនិះ ចុះបំពេញការងារ |
| | | | 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" | ជួលមធ្យោបាយដឹកជញ្ជូនដើម្បីចុះបំពេញការងារដូចជា÷ កង់ ម៉ូតូ ត្រីចក្រយានយន្ត រ៉ឺម៉ក រថយន្ត ជាដើម |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | | 61121 "សោហ៊ុយដឹកជញ្ជូន"<br>61122 "សោហ៊ុយបេសកកម្ម"<br>61123 "សោហ៊ុយស្នាក់នៅ" | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្ម ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |
| | | -ចំណាយរៀបចំកិច្ចប្រជុំ សិក្ខាសាលា/បណ្តុះបណ្តាលរបស់ភ្នាក់ងារសង្គមកិច្ច/ជំនួយការសង្គម | 61041 "សោហ៊ុយបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេស" | សកម្មភាពនៃការផ្តល់ចំណេះដឹង ឬ ជំនាញជាក់លាក់ណាមួយក្នុងគោលដៅអភិវឌ្ឍសមត្ថភាពដល់អ្នកចូលរួមពាក់ព័ន្ធ |
| | | | 61103 "ប្រជុំ សិក្ខាសាលា និងសន្និសីទ" | សកម្មភាពនៃការផ្សព្វផ្សាយការពិគ្រោះយោបល់ ការណែនាំ ឬ ការផ្លាស់ប្តូរបទពិសោធន៍ដល់អ្នកចូលរួមពាក់ព័ន្ធ |
| ៦. កិច្ចគាំពារសង្គម | ពង្រឹងសមត្ថភាពឃុំសង្កាត់ក្នុងការរៀបចំផែនការ និងអនុវត្តគម្រោងសេវាសង្គម/គាំពារសង្គម | -ចំណាយបៀវត្សរ៍ (ប្រាក់ឧបត្ថម្ភ) សម្រាប់ជំនួយការសង្គម/ភ្នាក់ងារសង្គមកិច្ចរបស់ឃុំ សង្កាត់ | 61091"ចំណាយលើការជួលទីប្រឹក្សា និងអ្នកជំនួយការជាជនជាតិខ្មែរ និងបុគ្គលិកជាប់កិច្ចសន្យាដែលជ្រើសរើសដោយរដ្ឋបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផ្ទាល់" | យោងប្រកាសលេខ ១១២៩ សហវ.ប្រក ចុះថ្ងៃទី១២/១០/២០១៨ |

| វិស័យ/អនុវិស័យ | គម្រោង/អន្តរាគមន៍ | មុខចំណាយដែលអាចប្រើប្រាស់ថវិកាគាំទ្រពីរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ | មាតិកាថវិកាសេដ្ឋកិច្ច (យោងប្រកាស៥២៣ សហវ.ប្រក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៧ និងប្រកាស១១២៩ សហវ.ប្រក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៨) | កំណត់សម្គាល់ |
|---|---|---|---|---|
| | | ចំណាយធ្វើដំណើរសម្រាប់កំណត់អត្តសញ្ញាណកុមារ និងស្ត្រីងាយរងគ្រោះ (កុមារក្រីក្រ រាប់បញ្ចូលទាំងកុមារពិការ និងកុមារដែលត្រូវបានទុកចោលដោយសារឪពុកម្តាយធ្វើចំណាកស្រុក ព្រមទាំងកុមារនិងស្ត្រីដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ) | 60015 "ប្រេងឥន្ធនៈនិងប្រេងរំអិល" | ទិញប្រេងឥន្ធនៈសម្រាប់យានជំនិះ ចុះបំពេញការងារ |
| | | | 61021 "ការជួលមធ្យោបាយដឹកជញ្ជូន" | ជួលមធ្យោបាយដឹកជញ្ជូនដើម្បីចុះបំពេញការងារដូចជា÷ កង់ ម៉ូតូ ត្រីចក្រយានយន្ត រ៉ឺម៉ក រថយន្ត ជាដើម |
| | | | 61121 "សោហ៊ុយដឹកជញ្ជូន"<br>61122 "សោហ៊ុយបេសកកម្ម"<br>61123 "សោហ៊ុយស្នាក់នៅ" | សម្រាប់មន្ត្រីរាជការសាធារណៈ និងមន្ត្រីជាប់កិច្ចសន្យាដែលមានការទទួលស្គាល់ជាផ្លូវការពីក្រសួងមុខងារសាធារណៈ ដែលត្រូវទទួលបានប្រាក់បេសកកម្មស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន |
| | ជំនួយសង្គមសម្រាប់កុមារ និងគ្រួសារដែលងាយរងគ្រោះ | -ចំណាយលើជំនួយសង្គម/ប្រាក់ឧបត្ថម្ភសម្រាប់÷<br>ក) គ្រួសារក្រីក្រ ដើម្បីការពារការបែកបាក់កូនពីគ្រួសារ ឬគ្រួសារក្រីក្រដែលធ្វើសមាហរណកម្មកូនត្រឡប់មកវិញ<br>ខ) កុមារងាយរងគ្រោះ/ក្រីក្រ ដែលទុកចោលដោយឪពុកម្តាយដែលធ្វើចំណាកស្រុក<br>-បង្កលក្ខណៈ (ឧបត្ថម្ភជីវភាពគ្រួសារ) ឱ្យមានការធ្វើសមាហរណកម្មកុមារពីមណ្ឌលថែទាំចូលទៅក្នុងសហគមន៍វិញ | 62028 "ជំនួយសង្គមផ្សេងៗទៀត" | |

